# ព្រឹត្តបត្រព័ត៌មាន

## អំពីស្ត្រី



ជំរុញសមភាពយេនឌ័រក្នុងសង្គមមួយ ដែលស្ត្រីអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនមាន តុល្យភាព និងអាចកសាងសមត្ថភាពដើម្បី ក្លាយជាអ្នកមានភាពម្ចាស់ការ
http://women.open.org.kh

ឆ្នាំទី ៖ ០១ លេខ ៖ ០០១ ចេញផ្សាយសម្រាប់ខែមីនា ឆ្នាំ២០១០


## បទវិចារណកថា

### ស្ត្រី និងសិទ្ធិចំពោះការលែងលះ

"ស្ត្រី និងសិទ្ធិចំពោះការលែងលះ" ត្រូវបានពិភាក្សាក្នុង សិក្ខាសាលាមួយកាលពីថ្ងៃទី ១៧ មីនា កន្លងមកនេះ រៀបចំឡើងដោយអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ក្នុងគោលបំណងជួយស្វែងរកដំណោះស្រាយ និងផ្តល់អនុសាសន៍នានាក្នុងការជួយសម្រួលដល់ស្ត្រីកម្ពុជាទទួលបានភាពងាយស្រួល និងយុត្តិធម៌ក្នុងការលែងលះ និងការលែងលះដោយស្របច្បាប់។

ទំនៀមទម្លាប់ និងប្រពៃណីខ្មែរក៏មិនខុសគ្នាប៉ុន្មានពីបណ្តាប្រទេសដទៃៗទៀតនៅក្នុងបណ្តាប្រទេសអាស៊ីដែរ គឺថា កាលណាបានរៀបអាពាហ៍ពិពាហ៍ហើយ ស្ត្រីចង់បានបុរសជាស្វាមីជាគូអនាគតអស់មួយជីវិត។ ពួកគេពិតជាមិនចង់មានឈ្មោះថាជា "ស្ត្រីប្តី

(តទៅទំព័រទី ២)

## ទេពកោសល្យស្ត្រី និងបុរស

### ជនជាតិភាគតិច និងការយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារ

ដោយអង្គុយជុំគ្នាជាមួយប្រពន្ធនៅឯក្រោមយ៉ាបខាងក្រោយផ្ទះរបស់ខ្លួន លោក សេវ លន់ បាន និយាយដោយមានទឹកមុខរីករាយថា គាត់បានយល់ដឹងច្រើនពីផលវិបាកដែលបណ្តាលមកពីអំពីហិង្សា



លោក សេវ លន់ និងគ្រួសារ
រូបភាពដោយ៖ អង្គការសុខភាពផ្លូវចិត្តគ្មានព្រំដែន

ក្នុងគ្រួសារ។ ឆ្នាំនេះ សេវ លន់ មានវ័យ ៤២ ឆ្នាំហើយ។ គាត់រស់នៅជាមួយប្រពន្ធឈ្មោះ រម៉ាស ពើន អាយុ ៣៥ ឆ្នាំ ដោយមានកូនតូចៗ និងជំទង់ៗចំនួន៥នាក់នៅក្នុងបន្ទុក។ គាត់ និងភរិយាជាកសិករ និងជាជនជាតិច្រាយ ដែលជាជនជាតិភាគតិចរស់នៅក្នុងភូមិសោមត្រក់ចាស់ ឃុំសោមធំ ស្រុកអូយ៉ាដាវ ខេត្តរតនគិរី ស្ថិតនៅភូមិភាគឦសាននៃប្រទេស។

ការរស់នៅរបស់គ្រួសារ សេវ លន់ មើលទៅដូចជាមានសុភមង្គល។ ជាមួយនឹងមុខរបរធ្វើស្រែ និងធ្វើចម្ការចន្ទី ដោយរួមទាំងចិញ្ចឹមមាន់ និងជ្រូកសម្រាប់លក់ដើម្បីជួយទ្រទ្រង់បន្ថែមដល់ជីវភាពប្រចាំថ្ងៃផង គ្រួសាររបស់គាត់មានជីវភាពមធ្យម ដោយមានហូបចុកគ្រប់គ្រាន់ មានសំលៀកបំពាក់

(តទៅទំព័រទី ៤)

## មាតិកា


- ជនជាតិភាគតិច និងការយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារ ទំព័រទី១
- ការស្វែងរកស្ទូចនាករ ដើម្បីសម្រេចផែនការសកម្មភាពជាតិ ទំព័រទី១
- អនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ទំព័រទី៣
- ស្ត្រីកម្ពុជា និងថ្ងៃ ៨ មីនា ទំព័រទី៤
- ការងារយេនឌ័រ និងសិទ្ធិស្ត្រីនៅក្នុងតំបន់ឦសាន ទំព័រទី៥
- យុវនារីក្មួយខ្មែរ! ថែរក្សាភាសាជាតិ! ទំព័រទី៧


## សង្គម និងការអភិវឌ្ឍន៍

### ការស្វែងរកស្ទូចនាករ ដើម្បីសម្រេចផែនការសកម្មភាពជាតិ

អំពើហិង្សាលើស្ត្រីកើតឡើងជាទូទៅនៅក្នុងប្រទេសកម្ពុជា ទោះបីជាមិនសូវត្រូវបានគេរាយការណ៍ក៏ដោយ ។ អំពើហិង្សាក្នុងគ្រួសារមានការកើនឡើងនៅកម្រិតខ្ពស់ក្នុងប៉ុន្មានទសវត្សរ៍កន្លងមក។ យើងអាចសន្មតជារួមថា ស្ត្រី១ នាក់ក្នុងចំណោម

(តទៅទំព័រទី ៦)



ទិដ្ឋភាពកិច្ចប្រជុំពិគ្រោះយោបល់
រូបភាពដោយ៖ អង្គការវិទ្យាស្ថានបើកទូលាយ

## បទវិចារណកថា

(តពីទំព័រទី ១)

ច្រើន" នោះឡើយ បើទោះជាស្វាមីរបស់ខ្លួនមានស្រីកំណាន់ ឬក៏ប្រពន្ធលើសពីមួយក៏ដោយចុះ ដោយពួកគេមិនចង់រស់នៅជាស្ត្រីមេម៉ាយ និងមិនចង់ឃើញកូនកំព្រាឪពុក។

ប៉ុន្តែស្ថានភាពនេះមានការប្រែប្រួល។ បច្ចុប្បន្ននេះជាសម័យកាលយេនឌ័រ ជាសម័យកាលបច្ចេកវិទ្យាព័ត៌មាន ដែលស្ត្រីមានការយល់ដឹងកាន់តែច្រើនជាងមុនពីសិទ្ធិស្របច្បាប់របស់ខ្លួនទាំងនៅក្នុងសង្គមគ្រួសារ ទាំងនៅក្នុងសង្គមជាតិ និងបានដឹងពីច្បាប់ដទៃៗទៀតក្នុងការការពារខ្លួនពីការរំលោភបំពាននានា ពិសេសការយល់ដឹងពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ និងច្បាប់ឯកពន្ធនភាព។ គេបានយល់ថា ស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។ មាត្រា៣៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចែងថា "ប្តី ឬ ប្រពន្ធ អាចប្តឹងសុំលែងលះគ្នាបាន កាលបើមានមូលហេតុគ្រប់គ្រាន់បញ្ជាក់ថា ខ្លួនពុំអាចរួមរស់ជាមួយគ្នាតទៅទៀតបាន..."។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ បានចែង (មាត្រា១) ធានាសមភាពរវាងសហព័ទ្ធក្នុងអាពាហ៍ពិពាហ៍ និងក្នុងគ្រួសារ ពង្រឹងការទទួលខុសត្រូវរបស់ឪពុកម្តាយក្នុងការចិញ្ចឹមថែរក្សាកូន និងជំរុញការបណ្តុះបណ្តាលសីលធម៌ និងការអប់រំកូន ដើម្បីអោយទៅជាពលរដ្ឋល្អ មានមនសិការស្នេហាជាតិ ស្រលាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម។

ការលែងលះគឺជាដំណោះស្រាយចុងក្រោយមួយដែលអស់ជម្រើស ហើយដែលវាបង្ហាញនូវភាពបរាជ័យក្នុងជីវិតគ្រួសារនៃគូស្វាមីភរិយា ដែលផលវិបាកនឹងធ្លាក់មកលើមិនត្រឹមតែអ្នកទាំងពីរនោះទេ តែវានឹងនាំមកនូវផលប៉ះពាល់ខ្លាំងដល់កូនៗទៀតផង។ ពេលខ្លះធ្វើឲ្យកូនៗទាំងនោះបាក់ទឹកចិត្ត លែងមានអារម្មណ៍កក់ក្តៅពីគ្រួសារ ហើយពួកគេចាប់ផ្តើមដើរមិនចូលផ្ទះក៏មាន ដែលបង្កឲ្យមានបញ្ហានៅគ្រួសារខ្លួនឯងផង និងដល់សង្គមជាតិផង។

ដូច្នេះ នៅពេលមានទំនាស់ គូស្វាមីភរិយាត្រូវចេះពិភាក្សាគ្នារកដំណោះស្រាយបញ្ហាដែលជាបញ្ហារួមនៅក្នុងជីវិតទាំងអស់គ្នាដើម្បីប្រយោជន៍គ្រួសារ។ ប្រសិនបើក្នុងករណីអ្នកទាំងពីរអស់ចិត្ត អស់មេត្រីភាព ហើយមិនចង់រួមសំវាសនឹងគ្នាបន្តទៀតនោះ គឺអ្នកទាំងពីរត្រូវតែស្រាយចំណងអាពាហ៍ពិពាហ៍នេះទៅតាមផ្លូវច្បាប់តាមរយៈតុលាការយុត្តិធម៌។

ចំពោះគូស្វាមីភរិយា ដែលរស់នៅជាមួយគ្នាដោយពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ អាចដោះស្រាយក្រៅប្រព័ន្ធតុលាការបាន តែបញ្ហានេះមានភាពស្មុគស្មាញច្រើន។ ដូច្នេះ គួរស្វាមី ភរិយាក្រៅពីការរៀបអាពាហ៍ពិពាហ៍ តាមទំនៀមទំលាប់ហើយនោះ ក៏ត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ដើម្បីក្លាយជាប្តីប្រពន្ធស្របច្បាប់។ សំបុត្រអាពាហ៍ពិពាហ៍ គឺជាឧបករណ៍មួយដែលអាចជួយស្ត្រីឲ្យទទួលបានផលប្រយោជន៍ពីការលែងលះជាមួយស្វាមី ព្រមទាំងកាត់បន្ថយនូវការខាតបង់ដែលស្ត្រីភាគច្រើនតែងជួបប្រទះក្នុងសំណុំរឿងលែងលះនោះ គឺការមិនទទួលបានការទទួលខុសត្រូវនៃការចិញ្ចឹមកូនពីសំណាក់ស្វាមី និងការបែងចែកទ្រព្យមិនស្មើគ្នាជាដើម។ ចុងក្រោយគឺបន្ទុកបានធ្លាក់ទៅលើស្ត្រីទាំងអស់៕

*សម្រាប់ឯកសារនេះជាអេឡិចត្រូនិក ៖*
*http://women.open.org.kh/km/women-divorce-rights*

## ក្រុមការងារកម្មវិធីស្ត្រី


លោកស្រី ជឹម ម៉ាណាវី
និពន្ធនាយក និងជានាយិកាប្រតិបត្តិ
លោក ឆាយ សុផល
អ្នកនិពន្ធ
កញ្ញា កៅ ពៅលក្ខិណា
ជំនួយការអ្នកគ្រប់គ្រងកម្មវិធីស្ត្រី
លោក នៅ វិច្ឆូរ
អ្នកគ្រប់គ្រងតំបន់បណ្តាញ
លោកស្រី ប្រាក់ សុខាយុ
អ្នកជំនួយការគម្រោង
លោក ម៉ក់ តារា
ជំនួយការបច្ចេកទេសទូទៅ
លោកស្រី អៀង កូឡា
អ្នករចនាទំព័រ
កញ្ញា សូ ចាន់នីម
អ្នកវាយអត្ថបទ


កម្មវិធីស្ត្រីនៃអង្គការវិទ្យាស្ថានបើកទូលាយ សូមថ្លែងអំណរគុណចំពោះមិត្តអ្នកអាន ដែលបានគាំទ្រប្រើប្រាស់វិបផតថលស្តីអំពីស្ត្រី និងព្រឹត្តិបត្រព័ត៌មានអំពីស្ត្រី។ ក្រុមការងារយើងខ្ញុំ សូមស្វាគមន៍នូវរាល់មតិយោបល់ ការរិះគន់ក្នុងន័យស្ថាបនា និងការផ្តល់ជាអត្ថបទ ឬបទសម្ភាសន៍របស់មិត្តអ្នកអាន ដែលមានខ្លឹមសារសមស្របទៅនឹងគោលបំណងរបស់កម្មវិធីស្ត្រី ដើម្បីចុះផ្សាយលើវិបផតថលស្តីអំពីស្ត្រី និងព្រឹត្តិបត្រព័ត៌មានអំពីស្ត្រី ។


ក្រសួងព័ត៌មាន
MINISTRY OF INFORMATION
លេខ...៤៨៥...ព.ម.

ព្រឹត្តិប័ត្រព័ត៌មានអំពីស្ត្រី ទទួលបានច្បាប់អនុញ្ញាតិចេញផ្សាយពីក្រសួងព័ត៌មាន តាមលិខិតលេខ ៤៨៥ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៩

## ច្បាប់ និងសិទ្ធិ

### អនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ

អនុម័ត និងបើកឲ្យចុះហត្ថលេខា ឲ្យសច្ចាប័ន និងឲ្យចូលជាសមាជិកតាមសេចក្តីសម្រេចចិត្តលេខ ៣៤១១៨០ ចុះថ្ងៃទី ១៨ ធ្នូ ឆ្នាំ ១៩៧៩ របស់សន្និបាតអង្គការសហប្រជាជាតិ ចូលជាធរមាននៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៨១ ស្របតាមបទបញ្ញត្តិមាត្រា ២៧




### ការពន្យល់ដោយសង្ខេប

អនុសញ្ញាស្តីពី ការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ "ស៊ី ដ" គឺជាឧបករណ៍ដែលមានលក្ខណៈតាមស្តង់ដារអន្តរជាតិ ដែលត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៧៩ និងបានចូលជាធរមាន នៅឆ្នាំ១៩៨២ ។ មកដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០០៥ ប្រទេសចំនួន១៨០ ដែលត្រូវជា ៩០ភាគរយ នៃសមាជិកសរុបរបស់អង្គការសហប្រជាជាតិ បានក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះ ។

អនុសញ្ញា "ស៊ី ដ" បង្កើតនូវគោលការណ៍នៃសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ដែលមានលក្ខណៈជាសកល ។ អនុសញ្ញានេះស្វែងរកនូវការបង្កើតឲ្យមាននូវសមភាពនៃសិទ្ធិសម្រាប់ស្ត្រី ដោយមិនគិតអំពីស្ថានភាពគ្រួសារទេ គឺនៅគ្រប់វិស័យទាំងអស់ ដូចជា នយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និងពលរដ្ឋ ។ អនុសញ្ញានេះបានគាំទ្រដល់ច្បាប់ជាតិ ដែលមានចែងអំពីការហាមឃាត់ចំពោះការរើសអើង និងទទួលស្គាល់វិធានការបណ្តោះអាសន្នពិសេសដើម្បីបង្កើនល្បឿនក្នុងការបង្កើតឲ្យមានសមភាពរវាងបុរស និងស្ត្រី រួមបញ្ចូលទាំងការផ្លាស់ប្តូរលើការអនុវត្តតាមលក្ខណៈប្រពៃណី និងវប្បធម៌ ដែលផ្អែកទៅលើគំនិតនៃ "ភាពទាបជាង ឬខ្ពស់ជាង" របស់ភេទណាមួយ ឬលើតួនាទីដែលមានទស្សនៈលំអៀងផ្អែកយេនឌ័ររបស់ស្ត្រី និងបុរស ។

គណៈកម្មាធិការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨២ បន្ទាប់ពីអនុសញ្ញានេះបានចូលជាធរមាន ។ ការងារសំខាន់របស់គណៈកម្មាធិការនេះ គឺពិចារណាលើរបាយការណ៍ដែលរដ្ឋជាភាគីនៃអនុសញ្ញា "ស៊ី ដ" បានផ្ញើមកទាក់ទងនឹងការតាក់តែងច្បាប់ ការវិនិច្ឆ័យ ការងាររដ្ឋបាល និងវិធានការជាច្រើនទៀត ដែលត្រូវបានបង្កើតឡើង ដើម្បីធ្វើឲ្យកាន់តែមានប្រសិទ្ធិភាពទៅលើអនុសញ្ញានេះ ។ គណៈកម្មាធិការនេះ នឹងផ្តល់អនុសាសន៍ដល់រដ្ឋជាភាគីនូវលើជំហានដែលត្រូវធ្វើសម្រាប់ការអនុវត្តអនុសញ្ញា "ស៊ី ដ"។

### ពិធីសារតាមជម្រើសនៃអនុសញ្ញា "ស៊ី ដ"

ពិធីសារតាមជម្រើសនៃអនុសញ្ញា "ស៊ីដ" ត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ នៅខែធ្នូ ឆ្នាំ ១៩៩៩ ។ ពិធីសារលើអនុសញ្ញា "ស៊ី ដ" ប្រឹងប្រែង ដើម្បីផ្តល់ឲ្យស្ត្រីនូវសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងជាបុគ្គលម្នាក់ៗ ជាមួយនឹងគណៈកម្មាធិការ អំពីការរំលោភលើអនុសញ្ញា "ស៊ី ដ" ដោយរដ្ឋាភិបាលរបស់បុគ្គលផ្ទាល់ និងផ្តល់អំណាចដល់គណៈកម្មាធិការ ក្នុងការធ្វើការអង្កេតចំពោះករណីល្មើសដែលស្ត្រីរងគ្រោះនេះ ស្ថិតនៅក្នុងប្រទេសដែលជាហត្ថលេខីនៃពិធីសារតាមជម្រើសនេះ។ មកដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៦ មានរដ្ឋចំនួន ៧៦ ជារដ្ឋភាគីនៃពិធីសារតាមជម្រើសនេះ ។

ពិធីសារតាមជម្រើសនៃអនុសញ្ញា "ស៊ី ដ" ត្រូវបានអនុម័តដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នាសម័យប្រជុំលើកទី២ នីតិកាលទី៤ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៩ ។

*សម្រាប់ឯកសារនេះជាអេឡិចត្រូនិកៈ*
http://women.open.org.kh/km/cedaw_kh

## ទេពកោសល្យស្ត្រី និងបុរស

(តពីទំព័រទី ១)

សមរម្យ មានប្រាក់កាសសន្សំទុកសម្រាប់ឱ្យកូនទៅរៀនសូត្រ និងទុកខ្លះសម្រាប់ចំណាយនៅពេលមានឈឺស្កាត់ដែរ។

ដោយងាកមើលមុខភរិយា សេវ លន់ បានរៀបរាប់ទៅតាមការយល់ដឹងរបស់ខ្លួនថា "អំពើហិង្សាក្នុងគ្រួសារ គឺជាការវាយដំគ្នា ប្ដីវាយប្រពន្ធ ប្រពន្ធវាយកូនចៅ ឬក៏ជេរប្រទេចគ្នា ឈ្លោះប្រកែកគ្នា" ហើយអំពើនេះនាំឲ្យគ្មានសុភមង្គល និងអាចបែកបាក់គ្រួសារ។

គាត់បានបញ្ជាក់ថា អំពើបែបនេះនាំឱ្យខ្មាសអ្នកជិតខាងនៅក្នុងភូមិ ហើយថា គ្មានអំពើហិង្សា "គ្មានភាពស្មុគស្មាញនៅក្នុងគ្រួសារ ងាយស្រួលធ្វើការងារ ចំណេញការងារ និងវេលា ហើយគ្រួសារមានការរីកចំរើន ពិសេសមិនខុសច្បាប់រដ្ឋ"។ សេវ លន់ និងភរិយាបានយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារតាមការផ្សព្វផ្សាយមកដល់ភូមិរបស់ពួកគេ ពីសំណាក់មន្ទីរកិច្ចការនារី និងអង្គការសុខភាពផ្លូវចិត្តគ្មានព្រំដែន ហើយគាត់តែងតែចូលរួមនៅសហគមន៍របស់គាត់ក្នុងកិច្ចប្រជុំទាក់ទិននឹងការអភិវឌ្ឍភូមិ ច្បាប់ ទំនាស់ដីធ្លី និងពីសុខភាពជាដើម។

គាត់បាននិយាយថា "ខ្ញុំបានយល់ខ្លះ និងចាំបានខ្លះ ហើយខ្ញុំបាននិយាយជាមួយប្រពន្ធខ្ញុំថា កុំឈ្លោះគ្នា កុំវាយដំគ្នា ព្រោះវាមិនល្អទេ ហើយនាំឱ្យប៉ះពាល់អារម្មណ៍កូនៗ និងនាំឲ្យខ្មាសគេ" ហើយថា គាត់ក៏បានប្រាប់កូនៗរបស់គាត់កុំឲ្យឈ្លោះ និងវាយតប់គ្នាដែរ ព្រោះវានាំឲ្យគ្មានសុភមង្គល ហើយខាតបង់ពេលវេលារកស៊ី និងធ្វើកិច្ចការផ្សេងៗទៀតផង។

ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏សេវ លន់ បានឱ្យដឹងដែរថា នៅក្នុងភូមិរបស់គាត់ បើទោះជាមានអ្នកខ្លះបានយល់ពីផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារក៏ដោយ ក៏មានអ្នកខ្លះនៅមិនទាន់យល់ ពិសេសប្ដីប្រពន្ធក្មេងៗ ដែលពួកគេ "ឈ្លោះគ្នាច្រើន" ហើយបញ្ហានេះភាគច្រើនបណ្ដាលមកពីផឹកស្រាស្រវឹង"។

បើតាមការឱ្យដឹងពីមន្ត្រីអង្គការសុខភាពផ្លូវចិត្តគ្មានព្រំដែនដែលបំពេញការងារនៅក្នុងខេត្តរតនគិរីបានឱ្យដឹងថា ការយល់ដឹងរបស់ជនជាតិភាគតិចនៅក្នុងខេត្តរតនគិរីអំពីអំពើហិង្សានៅមានកម្រិតទាបបំផុត ខណៈដែលការអប់រំផ្សព្វផ្សាយមិនទៅដល់គ្រប់សហគមន៍នៅឡើយ។

លោក វ៉ឹង ប៊ូរ៉ាន់ ប្រធានគម្រោងនៃអង្គការសុខភាពផ្លូវចិត្តគ្មានព្រំដែនបានបញ្ជាក់ថា វិធីនៃការអប់រំផ្សព្វផ្សាយមិនទាន់បត់បែនទៅតាមស្ថានភាពវប្បធម៌ និងប្រពៃណីរបស់ពួកគេ ជាពិសេសការប្រើប្រាស់ភាសាជាកត្តាដ៏លំបាកក្នុងការផ្ទេរចំណេះដឹងដល់ពួកគេ ហើយថាបញ្ហាសំខាន់នៃអំពើហិង្សា គឺបណ្ដាលមកពី "ការប្រើប្រាស់គ្រឿងស្រវឹង ការប្រច័ណ្ឌ និងភាពក្រីក្រ ហើយជាពិសេសរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងពេក"។

លោកបានបន្ថែមថា កត្តាសំខាន់ដើម្បីជួយកាត់បន្ថយបញ្ហានេះ គឺការផ្សព្វផ្សាយនៅតាមសហគមន៍ទាំងអស់ ដោយប្រើប្រាស់ជាភាសាដើមរបស់ពួកគេ ព្រមទាំងប្រើប្រាស់សម្ភារៈអប់រំទៅតាមស្ថានភាពវប្បធម៌ប្រពៃណីរបស់ពួកគេផងដែរ៕

## ទិវានារីអន្តរជាតិ ៨ មីនា

### ស្ត្រីកម្ពុជា និងថ្ងៃ ៨ មីនា

ថ្ងៃទី ៨ មីនា គឺថ្ងៃដែលពិភពលោកនាំគ្នារំលឹកពីសិទ្ធិស្ត្រី។ "ទិវានារីអន្តរជាតិ" ជាថ្ងៃពិសេសសម្រាប់ស្ត្រីទូទាំងសាកលលោក។ ប្រទេសជាច្រើនក្នុងចក្រវាឡនេះ ដែលក្នុងនោះរួមមានទាំងកម្ពុជាផងបានកំណត់ទិវានេះថាជាថ្ងៃបុណ្យរបស់ខ្លួន។ ដើម្បីមិត្តអ្នកអានបានដឹងអំពីខ្លឹមសារទិវានារីអន្តរជាតិ យើងសូមដកស្រង់ផ្សព្វផ្សាយជូនអំពីប្រវត្តិសង្ខេបនៃទិវានេះ។

ទិវានារីអន្តរជាតិ (៨ មីនា) គឺជាទិវាមួយដែលនារីជុំវិញពិភពលោកប្រារព្ធពិធីដើម្បីរំលឹកអបអរសាទរ។ អង្គការសហប្រជាជាតិក៏ប្រារព្ធពិធីអបអរសាទរទិវានេះ និងប្រទេសជាច្រើនបានកំណត់ទិវានេះ ថាជាថ្ងៃបុណ្យ



លោកជំទាវ អ៊ឹង កន្ថាផាវី សំណេះសំណាលជាមួយនិស្សិតស្ត្រី ក្នុងពិធីតាំងពិព័រណ៍
រូបភាពដោយៈ អង្គការវិទ្យាស្ថានបើកទូលាយ

ជាតិរបស់ខ្លួនផងដែរ។ នៅពេលនារីក្នុងទ្វីបទាំងអស់ ដែលជាញឹកញាប់តែងត្រូវបែងចែកដោយព្រំដែនជាតិ និងដោយជាតិពន្ធុខុសគ្នា ដោយភាពខុសគ្នាខាងភាសា វប្បធម៌ សេដ្ឋកិច្ច និងនយោបាយ មកជួបជុំគ្នាដើម្បីធ្វើពិធីបុណ្យរំលឹកខួបទិវារបស់ខ្លួន គេអាចរំលឹកឡើងវិញអំពីប្រពៃណីដែលតំណាងឲ្យយ៉ាងតិចប្រាំបួនទសវត្ស នៃការតស៊ូដើម្បីសមភាព យុត្តិធម៌ សន្តិភាព និងអភិវឌ្ឍន៍។

ទិវានារីអន្តរជាតិ គឺជារឿងរបស់នារីសាមញ្ញ ដែលជាអ្នកកសាងប្រវត្តិសាស្ត្រ។ វាបានចាក់ឫស ក្នុងការតស៊ូរបស់នារី អស់ពេលរាប់សតវត្សដើម្បីចូលរួមក្នុងសង្គមដោយស្មើភាពជាមួយបុរស។ នៅក្នុងប្រទេសក្រិចដែលជាប្រទេសចំណាស់ លីស៊ីស្ត្រាតា (Lysistrata) បានផ្តើមគំនិតធ្វើកូដកម្មផ្លូវភេទប្រឆាំងនឹងបុរសដើម្បីបញ្ចប់សង្គ្រាម និងនៅអំឡុងបដិវត្តន៍បារាំង នារីក្នុងទីក្រុងប៉ារីស បានអំពាវនាវ

(តទៅទំព័រទី ៧)

# បណ្តាញ និង អង្គការស្ត្រី

## ការងារយេនឌ័រ និងសិទ្ធិស្ត្រីនៅក្នុងតំបន់ព្រៃសាន

ដើម្បីយល់ដឹងពីកិច្ចការមួយចំនួនទាក់ទិននឹងយេនឌ័រ និងសិទ្ធិស្ត្រី ចំពោះស្ត្រីនៅតំបន់ភូមិភាគព្រៃសាននោះ អង្គការវិទ្យាស្ថានបើកទូលាយបានធ្វើបទសម្ភាសន៍ខ្លីមួយជាមួយលោកស្រី Yolanda Martinez អ្នកសម្របសម្រួលប្រចាំតំបន់អាស៊ីនៃអង្គការសន្តិភាព និងអភិវឌ្ឍន៍ ដែលក្នុងចំណោមកម្មវិធីរបស់អង្គការ មានកម្មវិធីមួយធ្វើនៅតំបន់ភូមិភាគព្រៃសាននៃប្រទេសកម្ពុជាផងដែរ។



លោកស្រី Yolanda Martinez ជួបប្រជុំជាមួយក្រុមការងារក្នុងការិយាល័យរបស់លោកស្រី
រូបភាពដោយ៖ អង្គការសន្តិភាព និងអភិវឌ្ឍន៍

*សំណួរ៖ តើមានបញ្ហាចម្បងអ្វីខ្លះ ដែលអង្គការកំពុងព្យាយាមដោះស្រាយ? ហើយចាប់ផ្តើមពីពេលណាមក?*

*ចម្លើយ៖* អង្គការសន្តិភាព និងអភិវឌ្ឍន៍អនុវត្តកម្មវិធីយេនឌ័រអស់រយៈពេល ០៤ឆ្នាំ មកហើយ "ដើម្បីបង្កើនឱកាស និងលើកកម្ពស់តួនាទីស្ត្រីកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ" ដោយផ្តោតលើបីផ្នែកសំខាន់ៗ យេនឌ័រ និងសិទ្ធិស្ត្រី ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម និងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។ យើងអនុវត្តកម្មវិធីនេះនៅភូមិភាគព្រៃសាននៃប្រទេសកម្ពុជា ដែលក្នុងនោះរួមមានខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី ហើយយើងបានចាប់ផ្តើមអនុវត្តនៅខែឧសភា ឆ្នាំ២០០៨ ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិដើម្បីស្ត្រី អង្គការពលកម្មអន្តរជាតិ និងអង្គការក្នុងស្រុកមួយចំនួន។

*សំណួរ៖ តើគម្រោងនេះទទួលបានជោគជ័យ និងមានអ្វីប្រែប្រួលខ្លះ ?*

*ចម្លើយ៖* ថ្វីត្បិតតែវាហាក់ដូចជាឆាប់ពេកក្នុងការបង្ហាញពីលទ្ធផល នៃការអនុវត្តគម្រោងកន្លងមក ប៉ុន្តែយើងមានជំនឿចិត្តថា ការផ្លាស់ប្តូរក្នុងការធ្វើការងារប្រកបដោយទស្សនៈយេនឌ័រចាប់ផ្តើមកើតឡើងក្នុងក្រុមគោលដៅរបស់យើង។ ឧទាហរណ៍ជាក់ស្តែង ដូចជានៅថ្នាក់មន្ទីរ និងអង្គការមិនមែនរដ្ឋាភិបាលតាមខេត្តក្រុមគោលដៅចាប់ផ្តើមផ្លាស់ប្តូររបៀបនៃការធ្វើការឆ្ពោះទៅរកទស្សនៈយេនឌ័រ ក៏ដូចជាបញ្ចូលទស្សនៈយេនឌ័រនៅក្នុងផែនការផងដែរ។

*សំណួរ៖ តើអ្វីខ្លះជាឧបសគ្គចម្បងៗរបស់អង្គការ?*

*ចម្លើយ៖* ចំណែកឧបសគ្គដែលរាំងស្ទះចំពោះការអនុវត្តកម្មវិធីនេះ រួមមានចំណេះដឹងរបស់ក្រុមគោលដៅនៅមានកម្រិត ទំនៀមទម្លាប់ប្រពៃណី និងភាសាខុសៗគ្នារបស់ក្រុមគោលដៅ តំបន់គោលដៅជាតំបន់ដាច់ស្រយាលបំផុត ដូចនេះ វាមានការលំបាកក្នុងការធ្វើដំណើរនៅរដូវវស្សា។

*សំណួរ៖ តើអ្វីដែលជាបញ្ហាប្រឈមចំពោះបញ្ហាដែលគម្រោងកម្មវិធីរបស់លោកស្រីបាននឹងកំពុងធ្វើ?*

*ចម្លើយ៖* បញ្ហាប្រឈមដែលយើងជួបប្រទះមាន២ សំខាន់ៗ រួមមាន ការធ្វើការងារយេនឌ័រ គឺជាការជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថ ប៉ុន្តែវាត្រូវការពេលវេលាយូរក្នុងការធ្វើរឿងនេះ ព្រោះមនុស្សម្នាក់ៗរស់នៅតាមទម្លាប់របស់ខ្លួនជាយូរណាស់មកហើយ។ ការប្រឈមមួយទៀតគឺ ធនធានមនុស្ស និងហិរញ្ញវត្ថុពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័ររបស់មន្ទីរថ្នាក់ខេត្តនៅមានកម្រិត។

*សំណួរ៖ តើលោកស្រីមានផែនការ និងអនុសាសន៍ដូចម្តេចដើម្បីជំនះលើឧបសគ្គទាំងនោះ?*

*ចម្លើយ៖* យើងបានព្យាយាមវិភាគជាមួយក្រុមគោលដៅនូវផលប៉ះពាល់អវិជ្ជមាននៃឥរិយាបថ និងស្ថានភាពបច្ចុប្បន្ន ព្រមទាំងបង្ហាញនូវសិទ្ធិស្ត្រីដែលមានក្នុងច្បាប់ ហើយបង្ហាញអំពីផលប្រយោជន៍នៃការផ្លាស់ប្តូរ ដើម្បីឱ្យពួកគេអាចធ្វើការផ្លាស់ប្តូរ និងកែប្រែដោយខ្លួនឯង។ ម៉្យាងវិញទៀត យើងបានព្យាយាមរៀបចំឯកសារ និងវិធីសាស្ត្រអប់រំឱ្យសាមញ្ញបំផុតតាមតែអាចធ្វើទៅបាន ដើម្បីឱ្យក្រុមគោលដៅងាយយល់។ លើសពីនេះទៀត យើងផ្តល់ការគាំទ្រខាងបច្ចេកទេសដល់ក្រុមគោលដៅ ដើម្បីឱ្យពួកគាត់ចេះធ្វើការងារតាមរយៈការដកពិសោធន៍ការងារជាក់ស្តែង។ មិនតែប៉ុណ្ណោះ យើងធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការតាមមូលដ្ឋាន ព្រោះពួកគេយល់ច្បាស់ពីស្ថានភាព។



សកម្មភាពរបស់អង្គការសន្តិភាព និងអភិវឌ្ឍន៍
រូបភាពដោយ៖ អង្គការសន្តិភាព និងអភិវឌ្ឍន៍

*សំណួរ៖ តើលោកស្រីមានសារអ្វីសម្រាប់ផ្ញើជូនសាធារណជន និងស្ត្រី?*

*ចម្លើយ៖* សមភាពយេនឌ័រគឺមិនមែនប្រឆាំងនឹងបុរសនោះទេ ប៉ុន្តែវាផ្តល់ប្រយោជន៍ដល់ទាំងបុរស និងស្ត្រី។ យើងសូមឱ្យស្ត្រីទាំងអស់ព្យាយាមបន្តការខិតខំប្រឹងប្រែងទៀតដូច្នេះយើងនឹងទទួលបានលទ្ធផលក្នុងពេលឆាប់ៗខាងមុខនេះ។

*សម្រាប់ព័ត៌មានលម្អិតសូមចូលអានគេហទំព័រ http://www.pydcambodia.org ឬទំនាក់ទំនងលេខ៖ (៨៥៥-២៣) ៩៩៤ ៧៤១*

## សង្គម និងការអភិវឌ្ឍន៍

(តពីទំព័រទី ១)

៧នាក់ ឬ១នាក់ក្នុងចំណោម ៥នាក់ ធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវកាយអំពីប្ដីរបស់ខ្លួន ហើយស្ត្រី ១នាក់ ក្នុងចំណោម ៥នាក់ ឬ ១នាក់ក្នុងចំណោម ៤នាក់ធ្លាប់ទទួលរងអំពើហិង្សាលើផ្លូវចិត្ត រូបកាយឬផ្លូវភេទ។



លោកស្រី ជូ សុខផានី អគ្គលេខាធិការរង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
រូបភាពដោយៈ អង្គការវិទ្យាស្ថានបើកទូលាយ

របាយការណ៍ករណីរំលោភ ក៏មានការកើនឡើង។ ទិន្នន័យអំពីការកេងប្រវ័ញ្ចខាងផ្លូវភេទមិនអាចរកបានទេ ទោះបីជានៅក្នុងសង្គមកម្ពុជា ករណីនេះកើតឡើងជាញឹកញាប់ក៏ដោយ។ គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រី កើតឡើងក្រោមការលាក់កំបាំងនៃភាពស្ងៀមស្ងាត់ និងការខ្មាសអៀន ព្រោះខ្លាចសង្គមមិនទទួលស្គាល់ និងកាតព្វកិច្ចដើម្បីរក្សាកេរ្តិ៍ឈ្មោះគ្រួសារទាំងមូល ហើយជនល្មើសកម្រនឹងត្រូវបានដាក់ទោសណាស់។

រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន បាននឹងកំពុងធ្វើការដើម្បីការពារសិទ្ធិស្ត្រី និងទប់ស្កាត់អំពើហិង្សាលើស្ត្រី។ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ ២០០៩-២០១២ (http://women.open.org.kh/km/national-action-plan-kh) បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ហើយត្រូវបានក្រសួងកិច្ចការនារីផ្សព្វផ្សាយជាផ្លូវការកាលពីខែកក្កដា ឆ្នាំ២០០៩ កន្លងមកនោះ គឺជាការណែនាំសម្រាប់ការធ្វើអន្តរាគមន៍តទៅមុខទៀត។ ផែនការនេះជាត្រីវិស័យសម្រាប់កំណត់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សេវាគាំទ្រស្ត្រី និងកុមាររងគ្រោះឲ្យពួកគេទទួលបាននូវសេវាសង្គម និងច្បាប់ប្រកបដោយគុណភាពគតិយុត្តិ និងសម្រេចបាននូវសូចនាករសំខាន់ៗ ដូចមានចែងក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងឈានទៅរកការលុបបំបាត់ និងទប់ស្កាត់អំពើហិង្សាលើស្ត្រីជាបណ្ដើរៗ។

ដើម្បីស្វែងរកយុទ្ធសាស្ត្រ ក្នុងកិច្ចសហការអនុវត្តផែនការជាតិនេះ ក្រសួងកិច្ចការនារី ជាមួយអង្គការវិទ្យាស្ថានបើកទូលាយ និងអង្គការសង្គមស៊ីវិលចំនួន ៤០ ផ្សេងទៀតដែលបំពេញការងារស្ត្រី និងសិទ្ធិ នៅដើមឆ្នាំនេះបានមកជួបជុំពិភាក្សាពិគ្រោះយោបល់គ្នាចំនួនពីរលើក អំពី "ការចូលរួមការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី"។ការពិគ្រោះយោបល់លើកដំបូងបានធ្វើឡើងនៅថ្ងៃទី១៧ កុម្ភៈ និងលើកទីពីរនៅថ្ងៃទី១២ មីនា ២០១០។



លោកស្រី Imma Calm និងលោក វ៉ឹង ប៉ូវ៉ាន់ នៃអង្គការ សុខភាពផ្លូវចិត្តគ្មានព្រំដែន
រូបភាពដោយៈ អង្គការវិទ្យាស្ថានបើកទូលាយ

កិច្ចពិគ្រោះយោបល់បានរកឃើញថា អំពើហិង្សាលើស្ត្រីមានការកើនឡើង



ទិដ្ឋភាពកិច្ចប្រជុំពិគ្រោះយោបល់
រូបភាពដោយៈ អង្គការវិទ្យាស្ថានបើកទូលាយ

ហើយកាន់តែធ្ងន់ធ្ងរឡើង រហូតដល់មានករណីឪពុកបង្កើតរំលោភកូនឯងក៏មាន។ បញ្ហាទាំងនេះគឺបណ្ដាលមកពីការអនុវត្តច្បាប់មានការធូររលុង និងចន្លោះប្រហោង ការចង់បង្ហាញអំណាចរបស់បុរសនៅក្នុងគ្រួសារ ការយល់ដឹងអំពីសិទ្ធិនៅមានកម្រិត ហើយព័ត៌មានមិនបានទៅដល់សហគមន៍ថែមទៀត។ អង្គប្រជុំក៏បានរកឃើញផងដែរនូវអំពើហិង្សាបែបថ្មីទៅលើស្ត្រី តាមរយៈនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដូចជាការបញ្ជូន និងជួញដូររូបភាព រួមទាំងរូបភាពអាសអាភាសជាដើម។ អនុសាសន៍មួយចំនួនត្រូវបានលើកឡើងនាពេលនោះរួមមាន ការបង្កើនការបណ្ដុះបណ្ដាលចំណេះដឹង និងផ្សព្វផ្សាយអំពីច្បាប់ឲ្យដល់សហគមន៍ដល់អាជ្ញាធរមូលដ្ឋាន ដោយផ្ដោតសំខាន់ទៅលើបុរស ។ គួរបញ្ចូលអនុសញ្ញា ស៊ី ដ ទៅក្នុងកម្មវិធីអប់រំ។ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (ICT) ដូចជាប្រព័ន្ធទូរស័ព្ទ អ៊ីមែល ការបង្កើតបញ្ជីអ៊ីមែលរួមដើម្បីបញ្ជូនសារឲ្យគ្នាទៅវិញទៅមក និងការបង្កើតប្រព័ន្ធទូរស័ព្ទហាត់ឡាញ (hotline) ដើម្បីផ្ដល់ព័ត៌មានឲ្យទាន់ពេលវេលា ក៏ជាយុទ្ធសាស្ត្រសំខាន់ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី៕

## ទិវានារីអន្តរជាតិ ៨ មីនា

(តពីទំព័រទី ៤)

រក "សេរីភាព សមភាព ភាតរភាព" ដោយដើរជាក្បួនឆ្ពោះទៅកាន់ទីក្រុងវែរសៃ ដើម្បីទាមទារសិទ្ធិបោះឆ្នោតសម្រាប់នារី។

ឆ្នាំ១៩១១ ជាលទ្ធផលនៃកិច្ចពិភាក្សាដែលបានសម្រេចនៅទីក្រុងCopenhagen កាលពីឆ្នាំមុន ទិវានារីអន្តរជាតិត្រូវបានគេធ្វើពិធីទទួលអបអរជាលើកដំបូង (នៅថ្ងៃទី១៩ ខែមីនា) នៅប្រទេសអូទ្រីស ប្រទេសដាណឺម៉ាក ប្រទេសអាល្លឺម៉ង់ និងប្រទេសស្វីស។

ឆ្នាំ១៩១៧ នារីរុស្ស៊ីជាថ្មីម្តងទៀតបានធ្វើកូដកម្ម ទាមទារ "ចំណីអាហារហូបចុក និងសន្តិភាព"។ បួនថ្ងៃក្រោយមកស្តេចរុស្ស៊ី (The Czar) ត្រូវបង្ខំឲ្យដាក់រាជ្យ ហើយរដ្ឋាភិបាលបណ្តោះអាសន្នបានផ្តល់សិទ្ធិបោះឆ្នោតដល់នារី។

សម្រាប់ប្រទេសកម្ពុជាវិញ រដ្ឋាភិបាលបានទទួលស្គាល់គុណបំណាច់នៃការចូលរួមរបស់ស្ត្រី ដោយចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ចំណេះដឹងថ្មី និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ធ្វើឲ្យស្ត្រីខ្មែរសប្បាយរីករាយក្នុងការទទួលនិងប្រើប្រាស់សិទ្ធិរបស់ខ្លួន មានឱកាសច្រើនក្នុងការចូលរួមក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ដូចជាការចូលរួមសកម្មភាពសង្គម និងបញ្ចេញមតិយោបល់ផ្សេងៗ។ ដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងជំរុញការចូលរួមរបស់ស្ត្រី ឲ្យបានច្រើនថែមទៀត ក្នុងគ្រប់វិស័យនយោបាយ សេដ្ឋកិច្ច សង្គម រដ្ឋាភិបាលកម្ពុជា តាំងពីឆ្នាំ២០០៦ បានបញ្ជ្រាបគោលនយោបាយយេនឌ័រ ទៅក្នុងរាល់ផែនការ និងគោលនយោបាយជាតិ។ ការចូលរួមរបស់ស្ត្រីក្នុងកម្រិតដឹកនាំ និងធ្វើសេចក្តីសម្រេចចិត្តមានការកើនឡើងជាលំដាប់។ ក្នុងការបោះឆ្នោតសកលឆ្នាំ២០០៨ កន្លងមក ស្ត្រីទទួលបាន ២៦ លើ ១២៣ កៅអី ក្នុងសភា ហើយជាប្រវត្តិសាស្ត្រ ស្ត្រីមួយរូប (លោកជំទាវ ម៉ែន សំអន) ត្រូវបានជ្រើសរើសជាឧបនាយករដ្ឋមន្ត្រីដំបូងគេនៅប្រទេសកម្ពុជា។ ក្នុងអាណត្តិទី៤ នៃរាជរដ្ឋាភិបាលកម្ពុជា មានស្ត្រី ១៨នាក់ ទទួលតំណែងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការក្រសួង និង ៣០នាក់ជាអនុរដ្ឋលេខាធិការ ថ្នាក់អភិបាលរងមាន ១៩៧ នាក់ និងថ្នាក់ក្រុមប្រឹក្សាសង្កាត់មាន ៨០០នាក់ក្នុងចំណោមស្ត្រីចំនួន ១៦៨៣ ជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៧។

ឆ្នាំនេះ ប្រទេសកម្ពុជាបានប្រារព្ធ "ទិវានារីអន្តរជាតិ" ក្រោមប្រធានបទ "រួមគ្នាបង្កើនសក្តានុពលរបស់ស្ត្រី និងយុវវ័យដើម្បីអភិវឌ្ឍន៍សង្គមជាតិ"។ ថ្លែងនៅក្នុងឱកាសពិធីអបអរសាទរខួបទី ៩៩ ទិវានារីអន្តរជាតិ ៨ មីនា ដែលបានប្រារព្ធធ្វើកាលពីព្រឹកថ្ងៃទី៨ មីនា កន្លងទៅនេះ នៅឯសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលរៀបចំឡើងដោយក្រសួងកិច្ចការនារី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក៏បានមានប្រសាសន៍រំលឹកពីសារសំខាន់នៃទិវានេះសម្រាប់ស្ត្រីទូទៅផងដែរ។ ជាមួយគ្នានោះ ក្រសួងកិច្ចការនារីក៏មានរៀបចំតាំងពិព័រណ៍



ទិដ្ឋភាពពិធីតាំងពិព័រណ៍
រូបភាពដោយៈ អង្គការវិទ្យាស្ថានបើកទូលាយ

ផលិតផលដែលជាស្នាដៃរបស់ស្ត្រី ដោយមានការចូលរួមជាច្រើនពីក្រសួង និងអង្គការមិនមែនរដ្ឋាភិបាល។

ស្ថាប័នផ្សេងៗទៀតនៅភ្នំពេញ និងខេត្តនានាក៏បានប្រារព្ធពិធីនេះរួមទាំងខេត្តរតនគិរី និងបន្ទាយមានជ័យ ដោយមានការចែកប័ណ្ណសរសើរដល់ស្ត្រីមានស្នាដៃ និង មានការចូលរួមបញ្ចេញមតិយោបល់អំពីកង្វល់របស់ស្ត្រីជនជាតិភាគតិចផងដែរ។

ទិវា ៨ មីនា ពិតជាមានអត្ថន័យសម្រាប់ស្ត្រី។ វាជាឱកាសសម្រាប់រំលេចអំពីស្នាដៃស្ត្រី។ សមិទ្ធផលខាងលើបានបង្ហាញឲ្យឃើញនូវស្នាដៃរបស់ស្ត្រីក្នុងការធ្វើឲ្យស្ថានភាពជីវិតរបស់ខ្លួនមានការប្រែប្រួលប្រសើរជាងព្រមទាំងបង្ហាញឲ្យសង្គមខ្មែរឃើញថា ពាក្យស្លោក "ស្ត្រីបង្វិលចង្ក្រានមិនជុំ" គឺលែងត្រឹមត្រូវទៀតហើយសម្រាប់ស្ត្រីខ្មែរ។

*ប្រវត្តិសង្ខេបនៃទិវានារីអន្តរជាតិ សូមអាននៅក្នុង* http://women.open.org.kh/international_women_day_history

## ចំណុចគន្លឹះក្នុងការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា

### យូនីកូដខ្មែរ! ថែរក្សាភាសាជាតិ!

អ្វីទៅជាយូនីកូដ? យូនីកូដ គឺជាខ្នាតគំរូអន្តរជាតិមួយដែលផ្តល់នូវតម្លៃលេខជាក់លាក់ សម្រាប់តួអក្សរនីមួយៗរបស់ភាសានានានៅលើពិភពលោក ដើម្បីប្រើប្រាស់នៅក្នុងកុំព្យូទ័រ ។ ភាសាខ្មែរក៏ស្ថិតនៅក្នុងខ្នាតគំរូនេះដែរ គឺគ្រប់ព្យញ្ជនៈ ស្រៈ និងសញ្ញានានាសុទ្ធតែមានលេខតំណាងក្នុងប្រព័ន្ធកុំព្យូទ័រ (យូនីកូដ) ។ យូនីកូដខ្មែរមិនមែនគ្រាន់តែជាពុម្ពអក្សរបន្ថែមមួយទៀតនោះទេ តែជាខ្នាតគំរូអន្តរជាតិថ្មីមួយសម្រាប់ភាសាខ្មែរ និងសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ។ កុំព្យូទ័រទូទាំងពិភពលោកនឹងយល់ ឬស្គាល់ភាសាខ្មែរ ពេលអ្នកប្រើពុម្ពអក្សរយូនីកូដ

(តទៅទំព័រទី ៨)

(តពីទំព័រទី ៧)

ខ្មែរ។ គ្រប់ពុម្ពអក្សរយូនីកូដទាំងអស់មានការបម្លែងកូដដូចៗគ្នា មានន័យថា ពេលដែលអត្ថបទមួយត្រូវបានវាយជាពុម្ពអក្សរយូនីកូដ នោះវាក៏អាចត្រូវបានផ្លាស់ប្តូរទៅជាពុម្ពអក្សរយូនីកូដផ្សេងទៀតបាន ហើយអត្ថបទនោះនឹងនៅរក្សាទ្រង់ទ្រាយយ៉ាងត្រឹមត្រូវ ។ ឧទាហរណ៍ អត្ថបទដែលវាយជាពុម្ពអក្សរយូនីកូដខ្មែរឈ្មោះ Khmer OS System នឹងត្រូវបានមើលឃើញដោយកុំព្យូទ័រផ្សេងដែលមិនមានពុម្ពអក្សរ Khmer OS System តែមានយូនីកូដ ។



ការវាយអត្ថបទដោយប្រើយូនីកូដខ្មែរ

## ហេតុអ្វីបានជាយើងត្រូវប្តូរទៅប្រើយូនីកូដខ្មែរ?

- យូនីកូដខ្មែរបានក្លាយជាទ្រង់ទ្រាយស្តង់ដារ សម្រាប់បម្លែងកូដអត្ថបទភាសាខ្មែរនៅក្នុងកុំព្យូទ័រ ។ គោលនយោបាយ ICT ថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជាក៏បានកំណត់ថាយូនីកូដខ្មែរជាគំរូស្តង់ដារជាតិ ។
- ប្រើយូនីកូដខ្មែរផ្តល់ភាពងាយស្រួលក្នុងការសរសេរអត្ថបទជាភាសាខ្មែរ និងអាចសរសេរបានលឿនបំផុត ។
- ដោយមានការទទួលស្គាល់ថាជាស្តង់ដារជាតិសម្រាប់ភាសាខ្មែរ ម៉ាស៊ីនស្វែងរកដូចជា Google, Yahoo... បានអនុញ្ញាតឲ្យយើងអាចស្វែងរកព័ត៌មានទិន្នន័យ ឬអត្ថបទផ្សេងៗជាភាសាខ្មែរដែលប្រើពុម្ពអក្សរយូនីកូដខ្មែរតាមរយៈបណ្តាញអ៊ីនធឺណិត ។
- តាមរយៈការប្រើប្រាស់យូនីកូដខ្មែរ យើងអាចទំនាក់ទំនងគ្នាតាមរយៈអ៊ីមែល និងជជែកកម្សាន្ត (Chat) ជាភាសាខ្មែរបានយ៉ាងងាយស្រួល ។
- ជាមួយយូនីកូដខ្មែរ អ្នកអាចតម្រៀបអក្សរខ្មែរបានតាមលំដាប់អក្ខរក្រមនិងពិនិត្យអក្ខរាវិរុទ្ធនៃការសរសេរពាក្យខ្មែរបានយ៉ាងត្រឹមត្រូវ ។
- យូនីកូដខ្មែរកំពុងត្រូវបានដាក់ឲ្យប្រើប្រាស់នៅតាមបណ្តាស្ថាប័នរាជរដ្ឋាភិបាល សាលារៀន អង្គការក្រៅរដ្ឋាភិបាលនិងក្រុមហ៊ុនឯកជននានា ។

## តើខ្ញុំធ្វើយ៉ាងដូចម្តេចដើម្បីបានយូនីកូដខ្មែរមកប្រើប្រាស់?

អ្នកអាចស្វែងរកទិញស៊ីឌីកម្មវិធីកុំព្យូទ័រភាសាខ្មែរដែលបានកម្មវិធីយូនីកូដខ្មែរនៅក្នុងនោះ បាននៅតាមបណ្ណាគារឬអាចទាញយក (Download) កម្មវិធីដំឡើងយូនីកូដខ្មែរពីតំបន់បណ្តាញ www.khmeros.info ឬពីតំបន់បណ្តាញផ្សេងៗជាច្រើនទៀត ។ បើមានបញ្ហាសូមទំនាក់ទំនងមកអង្គការវិទ្យាស្ថានបើកទូលាយ ឬអ៊ីមែល support@khmeros.info ឬតាមរយៈកម្មវិធីជជែកកំសាន្ត irc://irc.uirc.net/khmeros ។

## កម្មវិធីយុត្តិធម៌ស្ត្រី នៃអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

- ផ្តល់ប្រឹក្សាផ្នែកច្បាប់ និងធ្វើការការពារតាមផ្លូវច្បាប់ដល់ស្ត្រី ក្នុងករណីលែងលះ រំលោភសេពសន្ថវៈ ជួញដូរ និងករណីអំពើហិង្សា ។
- ផ្តល់ការការពារតាមផ្លូវច្បាប់ និងជំនួយផ្នែកច្បាប់ដល់ស្ត្រីជាពិរុទ្ធជន ដែលកំពុងឃុំខ្លួនបណ្តោះអាសន្ន និងស្ត្រីទណ្ឌិត នៅក្នុងពន្ធនាគារខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ធំ និងព្រៃវែង។
- ផ្តល់ការបណ្តុះបណ្តាលច្បាប់ដល់មន្ត្រីរដ្ឋាភិបាលនៅក្នុងខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងសៀមរាប ។

### ទំនាក់ទំនងព័ត៌មាន៖

**ការិយាល័យភ្នំពេញ**
០២៣ ៨៨៣ ៩១៤/ ០១២ ៨២៦ ១៦១/ ០១៧ ៤៧១ ៧៩៤

**ការិយាល័យខេត្តកំពង់ឆ្នាំង**
០១២ ២១៥ ៥១៤/០១៧ ៧១៦ ៥១៦

**ការិយាល័យខេត្តកំពង់ស្ពឺ**
០១៧ ៧៧៩ ២៥៥/ ០១២ ៩១៧ ២៣៤

**ការិយាល័យខេត្តសៀមរាប**
០១២ ៧៩៥/ ០១២ ៥៥៥ ៤០៦

**ការិយាល័យខេត្តបាត់ដំបង**
០៥៣ ៧៣០ ៦៣៦/ ០១២ ៥៩៨ ៥៥៣/ ០១២ ២៩៣ ០៨០

**ការិយាល័យខេត្តព្រៃវែង**
០២៣ ៨៨៣ ៩១៤/ ០១២ ៨២៦ ១៦១/ ០១៧ ៤៧១ ៧៩៤

រៀបចំ និងបោះពុម្ពផ្សាយដោយ ៖

វិទ្យាស្ថានបើកទូលាយ
Open Institute

ផ្ទះលេខ ១៩ ផ្លូវ៣៧៤ (ទល់មុខសាលាសង្កាត់ទួលស្វាយព្រៃទី១)
ទូរស័ព្ទលេខ ៖ (៨៥៥-២៣) ២២៤ ៨២១
Website: http://open.org.kh; Email: women@open.org.kh

ឧបត្ថម្ភដោយ ៖

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN
aecid